# រចនាសម្ព័ន្ធការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ



# តួនាទីភារកិច្ចរបស់ផ្នែកនីមួយៗ នៃការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ

## ១.ផ្នែកគ្រប់គ្រង និងរក្សាឯកសារ

-គ្រប់គ្រងឯកសារ កាលប្បវត្តិ ការងារបណ្ណាល័យ ការងារបណ្ណាសារ ចងក្រងទិន្នន័យ ដោយប្រព័ន្ធអ៊ីនធឺណេត

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការអង្កេតស្រាវជ្រាវដោយធ្វើការសន្និដ្ឋាន វាយតម្លៃ និងលើកយោបល់ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តជូនលេខាធិការដ្ឋានតាមការកំណត់

## ២. ផ្នែក អភិវឌ្ឍព័ត៌មានវិទ្យា

-បង្កើតគេហទំព័ររបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងកម្មវិធីព័ត៌មានវិទ្យា សម្រាប់ការងារផ្សព្វផ្សាយ

-បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database)

## ៣. ផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម

-គ្រប់គ្រង Server និង Network

-ផ្តល់ប្រឹក្សាលើតម្រូវការ Hardware ដែលត្រូវប្រើប្រាស់ក្នុងស្ថាប័ន

-គ្រប់គ្រង ថែទាំ និងជួសជុលឧបករណ៍ សម្ភារបច្ចេកទេស រក្សាសុវត្ថិភាព ប្រព័ន្ធព័ត៌មានវិទ្យា

-រៀបចំវគ្គបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងជំនាញបច្ចេកទេសព័ត៌មានវិទ្យា និងគ្រប់គ្រងមន្ត្រីទទួលបន្ទុកបច្ចេកទេសព័ត៌មានវិទ្យា

-កសាងគោលការណ៍ ផែនការ វិធានការ វិធីសាស្ត្រ ដើម្បីធ្វើការអភិវឌ្ឍន៍បច្ចេកវិទ្យា និងគ្រប់គ្រងព័ត៌មានវិទ្យា ទូរគមនាគមន៍របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**៤. ផ្នែក គ្រប់គ្រងតាមដានត្រួតពិនិត្យ និងវិភាគទិន្នន័យ**

-សហការ និងធ្វើការប្រមែប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការពិនិត្យ វិភាគសន្និដ្ឋាន វាយតម្លៃរាល់សកម្មភាព ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស

-ទទួលបណ្ដឹងពាក់ព័ន្ធរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជាពិសេសស្ត្រី និងកុមារព្រមទាំងបែងចែក ដោយសហការស្រាវជ្រាវជាមួយ ក្រសួង នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ

-សហការធ្វើបច្ចុប្បន្នភាពលើការងារគ្រប់គ្រងស្ថិតិ មុខរបរ ឬសេវាកម្មកម្សាន្ត ទាក់ទងនឹងការកេងប្រវ័ញ្ចអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ

-សហការ តាមដានត្រួតពិនិត្យ លំហូរទេសន្តប្រវេសន៍ ការងារជ្រើសរើសពលករ និងការបញ្ជូនពលករទេសន្តប្រវេសន៍ទៅធ្វើការនៅក្រៅប្រទេស

-ទំនាក់ទំនងសហការតាមដានការងារបង្ការ បង្ក្រាប ការពារជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៦

**ប្រធានការិយាល័យ**

អ៊ិន មាន

បានឃើញ និងឯកភាព

បញ្ជូនមកលោកប្រធានលេខាធិការដ្ឋាន

ពិនិត្យ សម្រេច។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦

**អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក**